# កំណើនសេដ្ឋកិច្ច និងដីធ្លី – តើស្ត្រីនៅទីណា?

ស្របពេលដែលប្រទេសកម្ពុជាកំពុងទទួលបានកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ បើទោះជាពេលខ្លះ ពុំមានកម្រិតស្មើគ្នាក៏ដោយ ឥឡូវនេះដល់ពេលដែលត្រូវសួរសំណួរ ថាតើត្រូវធ្វើយ៉ាងណាឱ្យកំណើនសេដ្ឋកិច្ចនេះផ្តល់ផលដល់មនុស្សឱ្យបានកាន់តែច្រើននាក់។ ចំណុចសំខាន់មួយ នៅក្នុងសមីការនេះ គឺរបៀបដោះស្រាយបញ្ហាវិវាទដីធ្លី និងរបៀបធានាយ៉ាងណាឱ្យស្ត្រីអាចទទួលបានប្រយោជន៍ពីកំណើនដែលពួកគេរួមចំណែកធ្វើឱ្យមាន។

គេតែងនិយាយថា កំណើនសេដ្ឋកិច្ចរួមចំណែកធ្វើឱ្យមានសមភាពយេនឌ័រ ប៉ុន្តែមិនមែនមនុស្សគ្រប់គ្នាសុទ្ធតែយល់ស្របបែបនេះនោះទេ។ សេដ្ឋវិទូ Naila Kabeer និង Luisa Natali លើកឡើងថា ស្របពេលដែលសមភាពយេនឌ័ររួម ចំណែកនាំឱ្យមានកំណើនសេដ្ឋកិច្ច មិនមែនកំណើនសេដ្ឋកិច្ចចេះតែនាំឱ្យមានសមភាពយេនឌ័ររហូតនោះទេ។ កំណើនសេដ្ឋកិច្ចអាចពុំមានឥទ្ធិពល ឬនៅក្នុងករណីមួយចំនួន មានឥទ្ធិពលជាអវិជ្ជមានមកលើសមភាពយេនឌ័រទៅវិញ។

នៅក្នុងប្រទេសកម្ពុជា ស្ត្រីមានតួនាទីសំខាន់ នៅក្នុងកំណើនសេដ្ឋកិច្ច ទាំងតាមរយៈសកម្មភាពសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់របស់ពួកគេផង និងតាមរយៈការបំពេញ□□នាទីជាកម្លាំងពលកម្ម សម្រាប់ឧស្សាហកម្មនាំចេញធំៗផង។ ប៉ុន្តែការសម្លឹងមើលស្ត្រីតែត្រឹមនេះ នាំឱ្យមានការព្រួយបារម្ភអំពីស្ត្រីផ្សេងទៀត ដែលមិនបានទទួលការគិតគូរ។ ស្ត្រីដែលពុំមានឱកាសទាំងនេះ រួមមាន ស្ត្រីដែលជាទណ្ឌិតនៅមណ្ឌលអប់រំកែប្រែទី២ ឬ ម២ ដែលជាពន្ធនាគារសម្រាប់ស្ត្រីជាដើម។ ខណៈពេលដែលពួកគេមិនតំណាងឱ្យប្រជាពលរដ្ឋទូទៅ ពួកគេគឺជាតំណាងឱ្យប្រជាពលរដ្ឋកម្ពុជាមកពីផ្នែក ចម្រុះ ដែលជួបប្រទះនឹងអ្វីដែលត្រូវបានគេចាត់ទុកថា ជាការខកខានមិនបានទទួលប្រយោជន៍ពីការអភិវឌ្ឍដ៏ឆាប់រហ័សរបស់ប្រទេសនេះ។

ស្ត្រីម្នាក់ៗ ក្នុងចំណោមស្ត្រីទាំងនេះ សុទ្ធតែមានរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេ។

មានស្ត្រីចំនួន ១១នាក់ កំពុងត្រូវបានជាប់ឃុំឃាំង ដោយសារតែសកម្មភាព ពាក់ព័ន្ធជាមួយនឹងវិវាទដីធ្លី។ ស្ត្រីចំនួន ៧ នាក់ ត្រូវបានចាប់ខ្លួន កាលពីថ្ងៃទី១០ ខែវិច្ឆិកា ហើយមិនដល់ ២៤ ម៉ោងក្រោយផង ត្រូវរងការចោទប្រកាន់ និងផ្តន្ទាទោស ពីបទធ្វើឱ្យអាក់ខានដល់ចរាចរណ៍សាធារណៈ ក្រោមមាត្រា ៧៨ របស់ច្បាប់ចរាចរណ៍។ ស្ត្រីទាំងនេះបានអូសយកគ្រែមួយមកដាក់លើមហាវិថីមុនីវង្ស ក្នុងគោលបំណងជម្រុញឱ្យអាជ្ញាធរភ្នំពេញចាត់វិធានការដោះស្រាយបញ្ហាទឹកលិចកាលពីពេលថ្មីៗនេះ ដែលនាំឱ្យប៉ះពាល់ដល់ផ្ទះសម្បែងរបស់ពួកគេ។ ជាមួយនឹងការចាក់ដីបំពេញបឹងកក់ សម្រាប់ការអភិវឌ្ឍតំបន់ពាណិជ្ជកម្ម ការលិចលង់នៅក្នុងតំបន់នេះកាន់តែអាក្រក់ទៅៗ។

នៅថ្ងៃបន្ទាប់ ស្ត្រីចំនួន៣នាក់ ដែលជាសកម្មជនសិទ្ធិដីធ្លី បានតវ៉ាប្រឆាំងទៅនឹងការចាប់ខ្លួនស្ត្រីទាំងនេះ ហើយពួកគេក៏ត្រូវបានចាប់ខ្លួន និងផ្តន្ទាទោសពីបទរារាំងមន្ត្រីសាធារណៈ ដោយមានស្ថានទំងន់ទោសក្រោមមាត្រា ៥០៤ របស់ក្រមព្រហ្មទណ្ឌ។ ពួកគេទាំង ១០ នាក់ ត្រូវបានកាត់ឱ្យជាប់ពន្ធនាគារ ១ឆ្នាំ និងពិន័យ ២លានរៀល។ ពួកគេទាំងអស់បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការផ្តន្ទាទោសនេះ។

ទណ្ឌិតទី ១១ គឺជាស្ត្រីវ័យក្មេងម្នាក់ ដែលគ្រួសាររបស់ពួកគេបានតស៊ូប្រឆាំងនឹងការបណ្តេញចេញ ដែលអូសបន្លាយពេលជាច្រើនឆ្នាំមកហើយ និងត្រូវបានចាប់ខ្លួន កាលពីខែមុននេះ។ ពាក្យបណ្តឹងរបស់គ្រួសារនាង ដែលប្តឹងពីការបៀតបៀន និងការគំរាមកំហែង ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ រួមទាំង ការបំពុលសត្វដែលពួកគេចិញ្ចឹម និងការ ប៉ុនប៉ងដុតផ្ទះរបស់ពួកគេ ត្រូវបានទុកចោលនៅតុលាការ ខណៈពេលពាក្យបណ្តឹងប្រឆាំងគ្រួសារនេះពីខាងក្រុមហ៊ុន ដែលចង់ឱ្យពួកគេចាកចេញ កំពុងត្រូវបានចាត់ការយ៉ាងឆាប់រហ័ស។ នាងត្រូវបានចោទប្រកាន់ និងឃុំឃាំងរង់ចាំការកាត់ក្តី។

វិវាទដីធ្លីនៅកម្ពុជា ត្រូវបានគេរាយការណ៍យ៉ាងទូលំទូលាយ ហើយស្ត្រីទាំង១១នាក់នេះ គឺស្ថិតក្នុងចំណោមស្ត្រីផ្សេងទៀត ដែលតែងតែនាំមុខគេក្នុងការតស៊ូប្រឆាំងនឹងការបណ្តេញចេញ ឬស្វែងរកដំណោះស្រាយចំពោះអ្វីដែលពួកគេបានបាត់បង់។

បុរស និងស្ត្រី ទទួលរងផលប៉ះពាល់ខុសៗគ្នា ដោយសារការបណ្តេញចេញដោយបង្ខំ។ ដោយសារតែការទទួលខុសត្រូវរបស់ពួកគេ ក្នុងនាមជាអ្នកផ្តល់ការថែទាំចម្បងសម្រាប់សមាជិកគ្រួសារ ស្ត្រីជួបប្រទះនឹងសម្ពាធច្រើនមុខ នៅពេលដែលពួកគេបាត់បង់ប្រភពចំណូល និងការគាំទ្រ ក្រោយពេលមានការបណ្តេញចេញ ឬការផ្លាស់ប្តូរទីលំនៅរបស់ពួកគេ។ ខណៈពេលដែលមានបុរសជាច្រើននាក់ចាកចេញពីផ្ទះសម្បែង ដើម្បីស្វែងរកការងារធ្វើ ជារឿយៗស្ត្រីត្រូវរស់ពឹងខ្លួនឯងដើម្បីផ្គត់ផ្គង់ជីវភាពដល់កូនៗរបស់ពួកគេ។ ការសិក្សានានាបានរាយការណ៍ពីករណីខ្វល់ខ្វាយ បញ្ហាបាក់ស្បាត និងថប់អារម្មណ៍របស់ស្ត្រី ដែលរងផលប៉ះពាល់ ដោយសារការបណ្តេញចេញ និងការផ្លាស់ប្តូរទីលំនៅ។

កាលពីខែតុលាឆ្នាំ២០១៣រាជរដ្ឋាភិបាលកម្ពុជាបានរាយការណ៍ទៅកាន់ស្ថាប័នសហប្រជាជាតិ ដែលទទួលខុសត្រូវពិនិត្យតាមដានស្ថានភាពរបស់ស្ត្រី និងវឌ្ឍនភាពក្នុងការឈានទៅសម្រេចសិទ្ធិមនុស្សរបស់ស្ត្រី។ ស្ថាប័ននោះ ដែលមានឈ្មោះថា គណៈកម្មាធិការ CEDAW ដោយយកឈ្មោះតាមអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ បានទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនលទ្ធភាពទទួលបានដីធ្លី។ គណៈកម្មាធិការក៏បានបង្ហាញពីក្តីបារម្ភផងដែរថា ស្ត្រីកម្ពុជាជួបប្រទះនឹងការកំហិតក្នុងការទទួលបានដីធ្លី និងកម្មសិទ្ធិ ហើយត្រូវទទួលរងការបាត់បង់ទីលំនៅ និងការបណ្តេញចេញ ដោយសារតែសម្បទានដីធ្លីក្នុងទ្រង់ទ្រាយធំ និងការអភិវឌ្ឍតំបន់ប្រជុំជន។ គណៈកម្មាធិការនេះបន្តលើកឡើងថា អ្នកការពារសិទ្ធិមនុស្ស

ដែលតស៊ូមតិដើម្បីសិទ្ធិដីធ្លីរបស់ស្ត្រីជារឿយៗ ទទួលរងការសម្លុតគំរាម និងការឃាយឃីពីសំណាក់មន្ត្រីអនុវត្តច្បាប់។ គណៈកម្មាធិការនេះបានអំពាវនាវឱ្យរដ្ឋាភិបាល *“*ធ្វើការស៊ើបអង្កេត និងក្នុងករណីសមស្រប ផ្តន្ទាទោសលើករណីសម្លុតគំរាម និងយាយីរបស់មន្ត្រីអនុវត្តច្បាប់មកលើអ្នកការពារសិទ្ធិមនុស្ស ដែលតស៊ូមតិ ដើម្បីសិទ្ធិដីធ្លី។*”*

ប្រសិនបើគេពិនិត្យមើលបរិបទទូលំទូលាយនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ការតស៊ូស្វិតស្វាញរបស់ស្ត្រីទាំង១១នាក់នៅក្នុងការបន្តការទាមទាររបស់ពួកគេ អាចយល់បានថាមានអត្ថន័យយ៉ាងហោចណាស់ចំនួន២យ៉ាង៖ ពួកគេមិនត្រឹមតែមិនបានទទួលផលពីកំណើនដែលទទួលបានដោយប្រជាជនផ្សេងទៀតនោះទេ ប៉ុន្តែកំណើន *“*ដ៏លេចធ្លោ*”* របស់ប្រទេសកម្ពុជា មួយផ្នែកបានមកពីការបាត់បង់ដែលស្ត្រីទាំងនេះទទួលរងដោយផ្ទាល់។ ចុងក្រោយ ពួកគេមិនបានគិតថា ពួកគេទទួលបានសិទ្ធិទទួលបានយុត្តិធម៌ ដូចដែលធានាដោយរដ្ឋធម្មនុញ្ញនោះទេ ដូច្នេះហើយបានជាពួកគេសុខចិត្តលំបាកបង្ខំចិត្តធ្វើការតវ៉ាតាមដងផ្លូវសាធារណៈ។

ប្រទេសកម្ពុជាប្រឈមនឹងសំណួរថាតើត្រូវធ្វើបែបណា ដើម្បីឱ្យកំណើនសេដ្ឋកិច្ចមានភាពល្អប្រសើរ ចំពោះស្ត្រីកម្ពុជា។ ការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការ CEDAW គឺជាជំហានដាក់លាក់មួយ។ ការផ្តល់លទ្ធភាពឱ្យ មានចលនាស្ត្រីរស់រវើក និងមានភាពម្ចាស់ការដោយខ្លួនឯងនៅកម្ពុជា ដែលរាប់បញ្ចូលទាំងស្ត្រី ដែលជាសកម្មជនសិទ្ធិដីធ្លីផងនោះ គឺជាជំហានមួយទៀត។ ហើយចុងក្រោយ ការអនុញ្ញាតឱ្យមានសកម្មភាពតស៊ូមតិដោយសន្តិវិធី គឺជាជំហានដ៏សំខាន់មួយ ដើម្បីបង្ហាញឱ្យគេឃើញថា លទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជាផ្តល់ឱកាសដល់គ្រប់សម្លេងទាំងអស់ រួមទាំងសម្លេងរបស់ស្ត្រីផងដែរ។ ចុងក្រោយ សំណួរថាតើស្ត្រីនៅឯណា**?** អាចឆ្លើយបានល្អបំផុត ដោយស្ត្រីកម្ពុជាខ្លួនឯង។

១៩ ធ្នូ ២០១៤

លោកស្រី Wenny Kusuma ជាតំណាងប្រចាំប្រទេសរបស់អង្គការ *UN Women* នៅកម្ពុជា